# II ឯកសារបណ្ដាក្រសួង

## ១ . ទីស្តីការរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ

### សេចក្តីប្រកាស

ភ្នំពេញ . ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៣

### សេចក្តីប្រកាសរបស់ក្រសួងហិរញ្ញវត្ថុ

ក្រសួងហិរញ្ញវត្ថុ សូមទូលថ្វាយព្រះអង្គ ព្រះអង្គមាស់ និង សូមប្រកាសជូនដល់គ្រប់ក្រសួង ស្ថាប័ន ខេត្ត ក្រុង ជនរួមជាតិជាទីគោរពស្នេហា អោយបានជ្រាបថា : ចាប់ពីរដ្ឋាភិបាលជាតិបណ្ដោះអាសន្ននៃកម្ពុជាបានបដិសន្ធិរហូតដល់បច្ចុប្បន្ន ក្រសួងហិរញ្ញវត្ថុបានពិនិត្យឃើញថា :

- តម្លៃប្រាក់រៀល មានស្ថេរភាពល្អប្រសើរ
- គ្មានការបោះផ្សាយបន្ថែមក្រដាសប្រាក់គ្រប់ប្រភេទទៀតឡើយ
- ចំណូលថវិការដ្ឋ មានការកើនឡើងទ្វេរដង ជាហេតុនាំអោយមានតុល្យភាពថវិការដ្ឋឡើងវិញ
- ថ្លៃទំនិញនៅតាមទីផ្សារមានស្ថេរភាពល្អប្រសើរ ហើយមានមុខទំនិញខ្លះ អាចចុះថោកជាងមុន ។

ករណីនេះបានធ្វើ ោយជីវភាពរស់នៅរបស់មន្ត្រីរាជការ កងទ័ព នគរបាល ប្រជាពលរដ្ឋយើងមាន ការកើនឡើងមួយកំរិត ។

អនុលោមទៅតាមសេចក្តីត្រូវការនៃទីផ្សារ នាពេលបច្ចុប្បន្នដែលអាចធ្វើអោយថ្លៃទំនិញមានការថយ ចុះម៉្យាង និង ម៉្យាងទៀតដើម្បីរួមចំណែកដល់ដំណើរការវិវឌ្ឍន៍ឈានឡើង នៃជីវភាពរស់ នៅរបស់ ប្រជាពលរដ្ឋជាទីគោរពស្នេហានៃយើង ក្រសួងហិរញ្ញវត្ថុ សំរេចដាក់អោយធ្វើចរាចរលើទីផ្សារ ឡើងវិញ ចាប់ពីចុងខែ តុលា ឆ្នាំ ១៩៩៣ នេះតទៅ នូវក្រដាសប្រាក់ប្រភេទ ៥០ រៀល ខ្នាតតូច ក្នុងនោះក៏ នឹងបញ្ចូល ផងដែរ ក្នុងបរិមាណដ៏តិចតួច នូវក្រដាសប្រាក់ប្រភេទ ៥០ រៀល ខ្នាតតូចជាមួយនឹងក្រដាស ប្រាក់ប្រភេទ ១០០ រៀល , ២០០ រៀល និង ៥០០ រៀល ក្នុងការបើកប្រាក់បៀវត្សខែ តុលា ជូនមន្ត្រី រាជការ កងទ័ព នគរបាលម្នាក់ៗ។

សេចក្តីដូចបានទូលថ្វាយ និង ជំរាបជូនខាងលើនេះ សូមប្រជាពលរដ្ឋទាំងអស់ក្នុងទូទាំង រាជាណាចក្រកម្ពុជា ទទួលស្គាល់ការយកក្រដាសប្រាក់ប្រភេទ ៥០ រៀល មកប្រើប្រាស់ដើម្បីការទូទាត់ លក់ - ទិញ ទំនិញ និង សេវាកម្ម ផ្សេងៗ រវាងប្រជាពលរដ្ឋ ជាមួយប្រជាពលរដ្ឋ និង ប្រជាពលរដ្ឋជាមួយរដ្ឋ ចាប់ពីចុងខែ តុលា ឆ្នាំ ១៩៩៣ នេះតទៅ។

រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ

ហត្ថលេខា និង ត្រា **សម រង្ស៊ី**